# ៨ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាស លេខ ១២៦៥ ប្រក.អជប**

**ស្តីពីការចាត់តាំងមន្ត្រីរាជការអោយធ្វើជាដៃគូជាមួយ**

**ជំនាញការក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទ កម្ពុជា ឥណ្ឌូនេស៊ី**

( Indonesia- Cambodia Rural Development Project )

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមា សភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលឥណ្ឌូនេស៊ី និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញការពាក់ពាក់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

**សំរេច**

**ប្រការ ១** : ចាត់តាំងមន្ត្រីរាជការដែលមានឈ្មោះខាងក្រោមអោយធ្វើជាដៃគូរ ( Counterparts ) ជាមួយអ្នកជំនាញការឥណ្ឌូនេស៊ីក្នុងកម្មវិធី អភិវឌ្ឍន៍ជនបទកម្ពុជា ឥណ្ឌូនេស៊ី ( ICRDP ) :

- លោក **ហៀង ជុនធឿង** មន្ត្រីនាយកដ្ឋានសេដ្ឋកិច្ចជនបទ
- លោក **មិន សាម៉ុន** មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង

**ប្រការ ២** : មន្ត្រីរាជការដែលបានចាត់តាំងក្នុងប្រការ ១ មានភារកិច្ចសហការជាមួយអ្នកជំនាញការរបស់កម្មវិធី ICRDP ដើម្បី អោយកម្មវិធីនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

**ប្រការ ៣** : ខុទ្ទកាល័យ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានទាំង ២ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង និងសាមុីជន ត្រូវអនុវត្តតាម ប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ទេដ្ឋ ហុង ស៊ុនហួត**

* * *

## ៩ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងបរិស្ថាន

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាស លេខ ១១៦៤ បស្ថ**

**ស្តីពីការតែងតាំង និងតំលើងឋានៈមន្ត្រីរាជការ**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយ ព្រះរាជក្រម